


សុំពន្យល់អំពីការប្រលងជាប់នឹងប្រលងធ្លាក់។




ការជ្រើសរើសទូទៅ  គឺយោងលើលិខិតអង្កេតការនឹងពិន្ទុ,ពិន្ទុនៃការប្រលងចំណេះដឹង,ពិន្ទុនៃការជួបសម្ភាសន៍។

ហើយបើវិទ្យាលយ័មានប្រលងលក្ខណះពិសេសគឺបូកបញ្ចូលពិន្ទុនៃលក្ខណះពិសេសផងដែរ។

មានវិទ្យាលយ័ប្រភេទCreative school មិនមានការប្រលងចំណេះដឹងទេ។

សិស្សដែលបញ្ចប់ការសិក្សាអនុវិទ្យាលយ័ឯបរទេសមិនមានលិខិតអង្កេតការទេលិខិតអង្កេតការ។

「សៀវភៅមគ្គុទេសក៍ឬសៀវភៅណែនាំសម្រាប់ចូលរៀនវិទ្យាល័យរដ្ឋ ☞ p.11」

# ការជ្រើសរើសពិសេសសម្រាប់សិស្សបរទេសដែលរស់នៅក្នុងខេត្តជាដើម

ការប្រលងចំណេះដឹង



ការជួបសម្ភាសន៍



ជ្រើសរើសពិសេសសិស្សបរទេសដែលរស់នៅក្នុងខេត្តជាដើមគឺសម្រេចដោយពិន្ទុនៃការប្រលងចំណេះដឹងនឹងពិន្ទុនៃការជួបសម្ភាសន៍។

ការប្រលងចំណេះដឹងមាន3មុខវិជ្ជាគឺភាសាជប៉ុន,អង់គ្លេស,គណិតវិទ្យាហើយមានសរសេររបៀបអាននៅលើអក្សរខាន់ជិ។

「សៀវភៅមគ្គុទេសន៍ឬសៀវភៅណែនាំសម្រាប់ចូលរៀនវិទ្យាល័យរដ្ឋ ☞ p.16」




ការប្រលងជ្រើសរើសទូទៅក៍អាចអោយមានសរសេររបៀបអាននៅលើអក្សរខាន់ជិ

ដែរក៍ប៉ុន្តែ ចាំបាច់ត្រូវដាក់ពាក្យ។

សេចក្តីលម្អិតសូមអានលើទំព័រទី16នៃសៀវភៅណែនាំ។




សូមអានលើទំព័រទី7នៃសៀវភៅណែនាំ។　នេះគឺជាលិខិតអង្កេតការ។

លិខិតអង្កេតការ គឺសម្រាប់កត់ត្រាពិន្ទុសិក្សានៅអនុវិទ្យាលយ័នឹងកត់ត្រាសកម្មភាពនៅក្នុងសាលា សិស្សដែលរៀននៅអនុវិទ្យាលយ័។

គ្រូអនុវិទ្យាលយ័នឹងសរសេរហើយផ្ញើរទៅវិទ្យាលយ័ដែលសិស្សត្រូវប្រលងចូល។

សិស្សដែលបញ្ចប់អនុវិទ្យាលយ័នៅឯបរទេសមិនមានលិខិតអង្កេតការទេ។

សញ្ញាព្រួញពណ៌ខៀវគឺជាពិន្ទុគណិតវិទ្យានៅថ្នាក់ទី2　រាប់ពីភាសាជប៉ុន សរុបទៅមាន9មុខវិជ្ជា។

សញ្ញាព្រួញពណ៌ក្រហមគឺជាពិន្ទុនៅថ្នាក់ទី3

ការវាយតម្លៃសរុបក្នុង9មុខវិជ្ជានៅថ្នាក់ទី2នឹងវាយតម្លៃសរុបនៅថ្នាក់ទី3ហើយគុណនឹង2គឺជាការសម្រេចពិន្ទុសរុបក្នុងការវាយតម្លៃ។

ពិន្ទុសរុបក្នុងការវាយតម្លៃគឺសំខាន់ណាស់សម្រាប់ការប្រលងចូលវិទ្យាលយ័។